# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ១៣៥២ ព្រទ-២០០១

# រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
## ជម្រាបមក
## លោក..........ប្រធានតុលាការខេត្តស្វាយរៀង

**កម្មវត្ថុ:** ករណីដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

ខ្ញុំសូមជម្រាបលោកប្រធានថា ក្រសួងយុត្តិធម៌បានទទួលលិខិតលេខ ៧៧៦-២០០១ រ.ប.លដ ចុះថ្ងៃទី ៣០-០៨-២០០១ ។ របស់អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្សលីកាដូ ដែលបានប្តឹងថា លោកបានចេញដីកាចាប់ខ្លួនទណ្ឌិតជាអនីតិជនឈ្មោះ...ដាក់គុកបង្ខំដល់រូបកាយអស់រយៈពេល៥០ថ្ងៃ ចាប់ពីថ្ងៃទី១២-០៦-២០០១ រហូតដល់ថ្ងៃទី០២-០៨-២០០១ ដើម្បីទារសំណងប្រាក់ធនខណ្ឌក្នុងរឿងព្រហ្មខណ្ឌ ។

ករណីនេះ ក្រសួងបានចាត់នាយកដ្ឋានជំនាញឱ្យពិនិត្យសិក្សាឃើញថា សេចក្តីសម្រេចរបស់លោកមានលក្ខណៈមិនសមស្របទៅនឹងបញ្ញត្តិមាត្រា៤ វាក្យខ័ណ្ឌទី២នៃច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌទ្បើយ។បញ្ញត្តិមាត្រា៤ វាក្យខ័ណ្ឌទី២នេះចែងថា អនីតិជនអាយុតិចជាង១៨ឆ្នាំ និងមនុស្សវិកលចរិក មិនត្រូវដាក់គុកបង្ខំដល់រូបកាយដើម្បីទារប្រាក់ធនខណ្ឌនោះទេ ។

ហេតុដូច្នេះ ក្រសួងសូមឱ្យលោកយកចិត្តទុកដាក់ពិនិត្យសិក្សាឱ្យបានច្បាស់លាស់ទាំងអង្គហេតុ និងអង្គច្បាប់មុននឹងសម្រេចសេចក្តីអ្វីមួយជៀសវាងការប្រព្រឹត្តខុសឆ្គង ដែលជាហេតុនាំឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ដល់ប្រព័ន្ធនីត្យានុកូលភាពសង្គម និងជាពិសេសដល់ការគោរពសិទ្ធិមនុស្សតាមផ្លូវច្បាប់។

ទទួលបានការណែនាំនេះ សូមលោកយកជំហរទទួលខុសត្រូវឱ្យបានហ្មត់ចត់ក្នុងការដោះស្រាយសំណុំរឿង ហើយត្រូវពិនិត្យសិក្សាស្រាវជ្រាវច្បាប់ឱ្យបានល្អិតល្អន់ ហើយបើមានបញ្ហាស្រពិចស្រពិលមិនយល់ច្បាស់លើបញ្ហាអ្វី សូមលោកប្រញាប់រាយការណ៍មកក្រសួងជាបន្ទាន់ ដើម្បីក្រសួងជួយចាត់វិធានដល់ការបំភ្លឺតាមនីតិវិធីនៃច្បាប់តទៅ

ធ្វើនៅភ្នំពេញ ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០១

**រដ្ឋមន្ត្រី**

**អ៊ុក វិធុន**

ចម្លងជូន
-ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
-តុលាការកំពូល មហាអយ្យការអមតុលាការកំពូល
-សាលាឧទ្ធរណ៍
-មហាអយ្យអមសាលាឧទ្ធរណ៍
-តុលាការ អយ្យការអមតុលាការខេត្ត-ក្រុង
-ដើម្បីជ្រាប